OFFICE OF THE CITY CLERK
SERVING LONG BEACH SINCE 1897

# ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 សំណួរគេឧស្សាហ៍សួរ អំពីការបោះឆ្នោតសាកល

## ខ្ញុំជាពលរដ្ឋថ្មី ។ តើខ្ញុំចុះឈ្មោះបោះឆ្នោត បានដោយរបៀបណាដែរ ?

ក្រោយពេលមានពិធីរបស់សេវាចូលសញ្ជាតិ និងអន្តោប្រវេសន៍រួច លោកអ្នកអាចចុះឈ្មោះបោះឆ្នោតបាន

- សូមចូលទៅ https://registertovote.ca.gov/
- សូមស្នើសុំ ទម្រង់បែបបទចុះឈ្មោះបោះឆ្នោត តាមរយៈលេខ (562) 570-6101
- នៅមណ្ឌលបោះឆ្នោត រហូតដល់ថ្ងៃបោះឆ្នោត

## តើខ្ញុំអាចបោះឆ្នោតបានទេ ប្រសិនបើខ្ញុំធ្លាប់ជាប់ពន្ធនាគារ ឬ ផ្នែកមួយ នៃប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ

លោកអ្នកអាចបោះឆ្នោតបាន ប្រសិនបើលោកអ្នក :

- រួចពីការឃុំខ្លួន តែស្ថិតក្រោមការតាមដានមើល
- ស្ថិតក្រោមការតាមដានមើលនៅសហគមន៍ ក្រោយពេលចេញពីពន្ធនាគារ
- ស្ថិតក្រោមការតាមដានមើល ជាកំហិត
- នាពេលបច្ចុប្បន្ននេះ ស្ថិតនៅក្នុងពន្ធនាគាររបស់ខោនធី (លុះណាតែ លោកអ្នកជាប់ឃុំ ដោយសារលោកអ្នកបានរំលោភបំពាន លក្ខខណ្ឌដោះលែងមុនពេលកំណត់ ឬ ត្រូវបានកាត់សេចក្តី ហើយ ផ្តន្ទាទោស ពីបទឧក្រិដ្ឋ និង រង់ចាំផ្ទេរទៅពន្ធនាគាររដ្ឋ ឬ ពន្ធនាគារសហព័ន្ធ)
- ការចោទប្រកាន់បទឧក្រិដ្ឋ ត្រូវបានព្យួរ – មិនទាន់បានកាត់ក្តី
- កំពុងជាប់ឃុំខ្លួន ក្នុងពន្ធនាគារ ឬ រួចពីការឃុំខ្លួន តែស្ថិតក្រោមការតាមដានមើល ដោយសារជាប់ទោសមជ្ឈឹម

## តើខ្ញុំចាំបាច់ត្រូវចុះឈ្មោះបោះឆ្នោត នៅពេលណាដែរ សម្រាប់ការបោះឆ្នោតសាកល នាថ្ងៃទី 3 ខែវិច្ឆិកានោះ ?

ថ្ងៃចុងក្រោយ សម្រាប់ការចុះឈ្មោះបោះឆ្នោត គឺ **ថ្ងៃទី 19 ខែតុលា ឆ្នាំ 2020** រយៈពេល 15 ថ្ងៃ មុនថ្ងៃបោះឆ្នោតសាកល (**ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020**)
លោកអ្នកអាចចុះឈ្មោះបាន ដោយចូលទៅ https://registertovote.ca.gov/ ។

ប្រសិនបើលោកអ្នកខកពេលហួសកាលកំណត់នោះ លោកអ្នកត្រូវទៅចុះឈ្មោះ ដោយផ្ទាល់ នៅការិយាល័យអគ្រានុកូលដ្ឋាន-កំណត់ត្រា របស់ខោនធី LA ឬ នៅការិយាល័យបោះឆ្នោត ណាមួយក៏បាន ។

## តើការបោះឆ្នោត ចាប់ផ្តើមនៅពេលណាដែរ ?

- ការបោះឆ្នោត តាមប្រៃសណីយ៍ ចាប់ផ្តើមនៅ **ថ្ងៃទី 5 ខែតុលា ឆ្នាំ 2020**
- ការបោះឆ្នោត ដោយផ្ទាល់ ចាប់ផ្តើមនៅតាមមណ្ឌលបោះឆ្នោត នៅ **ថ្ងៃទី 24 ខែតុលា ឆ្នាំ 2020**

## តើខ្ញុំបញ្ជូនសន្លឹកឆ្នោតរបស់ខ្ញុំទៅវិញ បានដោយរបៀបណាដែរ ?

- បញ្ជូនទៅវិញតាម ទីតាំងប្រអប់សំបុត្រទទួលសន្លឹកឆ្នោត
- បញ្ជូនទៅវិញតាមប្រៃសណីយ៍ សូមចាំថា មិនបាច់មានបិទតែមនោះទេ
- បញ្ជូនទៅវិញ នៅតាមមណ្ឌលបោះឆ្នោត ក្នុងខោនធី LA
- បញ្ជូនទៅវិញ នៅការិយាល័យអគ្រានុកូលដ្ឋាន-កំណត់ត្រា របស់ខោនធី LA

## តើអ្នកផ្សេងទៀត អាចបញ្ជូនសន្លឹកឆ្នោត ជំនួសខ្ញុំបានទេ ?

បាន ម្ចាស់ឆ្នោតដែលមិនអាចបញ្ជូនសន្លឹកឆ្នោតខ្លួន តាមប្រៃសណីយ៍វិញបាន អាចចាត់ឱ្យបុគ្គលណាម្នាក់ បញ្ជូនសន្លឹកឆ្នោតពួកគេបាន ឱ្យតែមិនមានពាក់ព័ន្ធនឹងសំណងទូទាត់ សម្រាប់បុគ្គល ក្រុម ឬ គ្រឹះស្ថាន ដែលបញ្ជូនសន្លឹកឆ្នោតទៅវិញនោះ ។

## តើខ្ញុំចាំបាច់ត្រូវស្នើសុំ ដើម្បីអាចបោះឆ្នោត តាមប្រៃសណីយ៍ ដែរឬទេ ?

មិនបាច់ទេ ម្ចាស់ឆ្នោតនៅឡូងប៊ិច ដែលបានចុះឈ្មោះរួចទាំងអស់ នឹងទទួលបាន បញ្ញើសន្លឹកឆ្នោត តាមប្រៃសណីយ៍ ចាប់ផ្តើមពី **ថ្ងៃទី 5 ខែតុលា ឆ្នាំ 2020** ដោយមិនបាច់មានសំណើនោះទេ ។

## ប្រសិនបើខ្ញុំទទួលបាន បញ្ញើសន្លឹកឆ្នោត តាមប្រៃសណីយ៍ តើខ្ញុំនៅតែអាចទៅបោះឆ្នោត ដោយផ្ទាល់ នៅតាមណ្ឌលបោះឆ្នោត បានដែរឬទេ ?

បាន លោកអ្នកអាចសម្រេច បញ្ជូនសន្លឹកឆ្នោត របស់លោកអ្នក តាមប្រៃសណីយ៍វិញ ឬ ទុកសន្លឹកឆ្នោតវិញ ហើយ ចេញទៅបោះឆ្នោតដោយផ្ទាល់បាន ។

## ខ្ញុំមិនបានទទួល បញ្ញើសន្លឹកឆ្នោត តាមប្រៃសណីយ៍ របស់ខ្ញុំនោះទេ ។ តើខ្ញុំអាចស្នើសុំសន្លឹកឆ្នោត បានដែរឬទេ ?

លោកអ្នកអាចទំនាក់ទំនងទៅ ការិយាល័យអគ្រានុកូលដ្ឋាន-កំណត់ត្រា របស់ខោនធី LA តាមរយៈលេខ 800-815-2666 ។

## តើខ្ញុំអាចបញ្ជាក់ថាសន្លឹកឆ្នោតបោះតាមបញ្ញើប្រៃសណីយ៍របស់ខ្ញុំ ទទួលបានហើយ បានដោយរបៀបណាដែរ ?

- សូមចូលរួមប្រើកម្មវិធី Ballot Trax ដោយចូលទៅ : https://california.ballottrax.net/voter/
- សូមចូលទៅមើល ឧបករណ៍តាមដានបញ្ញើប្រៃសណីយ៍ របស់ការិយាល័យអគ្រានុក្រូលដ្ឋាន-កំណត់ត្រា នៃខោនធី LA ដោយចូលទៅ : https://www.lavote.net/av_inquiry

## ចុះបើខ្ញុំភ្លេចចុះហត្ថលេខា លើស្រោមសំបុត្រនោះ ?

- ការិយាល័យអគ្រានុក្រូលដ្ឋាន-កំណត់ត្រា របស់ខោនធី LA នឹងផ្ញើរ "លិខិតជម្រាបជូន អំពីសន្លឹកឆ្នោតមិនបានចុះហត្ថលេខា" ទៅ ដើម្បីស្នើសុំឱ្យលោកអ្នកចុះហត្ថលេខា ។
- ម្ចាស់ឆ្នោត មានរយៈពេល ម្ភៃប្រាំបី (28) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត សម្រាប់ផ្ញើរលិខិតនេះទៅវិញ ។

## តើខ្ញុំអាចរកទីតាំងរបស់ មណ្ឌលបោះឆ្នោត ឬ ប្រអប់ដាក់សន្លឹកឆ្នោត 24 ម៉ោង បានដោយរបៀបណាដែរ ?

សូមចូលទៅ : https://lavote.net/ ឬ http://www.longbeach.gov/cityclerk/

## តើប្រអប់ដាក់សន្លឹកឆ្នោត 24 ម៉ោង មានសុវត្ថិភាព ដែរឬទេ ?

មានសុវត្ថិភាព ដោយប្រអប់ដាក់សន្លឹកឆ្នោត 24 ម៉ោង ត្រូវបានស្ថាបនាឡើង ពីដែកថែបទាំងអស់ ហើយមានសណ្ឋានលក្ខណការពារសុវត្ថិភាព ជាច្រើនទៀត ។ ប្រអប់នេះ ត្រូវបានភ្ជាប់ទៅនឹងដី ដោយប្រើគន្លឹះភ្ជាប់បេតុង នៅផ្នែកខាងក្នុងប្រអប់ ដែលដុំខ្មៅមួលភ្ជាប់មិនលេចចេញមកនៅក្រៅនោះទេ ។ ប្រឡោះ មានទំហំតូចល្មម សម្រាប់ដាក់សន្លឹកឆ្នោត មួយសន្លឹកចុះ ហើយការពារមិនឱ្យមាន ទឹកចូល និង ការគូសវាសផ្តេសផ្តាស់ ។

## តើពេលណា ទើបសន្លឹកឆ្នោតនឹងត្រូវបានប្រមូលយកទៅ ?

សន្លឹកឆ្នោតនឹងត្រូវប្រមូលយក ដោយការិយាល័យអគ្រានុក្រូលដ្ឋាន-កំណត់ត្រា របស់ខោនធី LA ជារៀងរាល់សប្តាហ៍ នៅដំណាក់កាល នៃកំឡុងពេលបោះឆ្នោត ។ ការមកប្រមូលសន្លឹកឆ្នោត នឹងកើនឡើងញយដង នៅពេលខិតជិតដល់ ថ្ងៃបោះឆ្នោត ។ ប្រអប់ទាំងអស់នឹងត្រូវរក្សាទុក ប្រកបដោយសុវត្ថិភាព នៅម៉ោង 8:00 យប់ នាថ្ងៃបោះឆ្នោត ។

## តើរយៈពេលប៉ុន្មាន បន្ទាប់ពីថ្ងៃបោះឆ្នោត ដែលគេនៅតែទទួលយកសន្លឹកឆ្នោត ?

ការបោះឆ្នោត ដោយប្រើបញ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍ ដែលបញ្ញើប្រៃសណីយ៍មានបោះត្រាបញ្ជាក់ពេលវេលាដាក់ផ្ញើរចេញ មុន ឬ នៅថ្ងៃបោះឆ្នោត ហើយទទួលបាន ក្នុងរយៈពេល 17 ថ្ងៃ នឹងត្រូវឆ្លងដំណើរការ ផ្ទៀងផ្ទាត់ និង រាប់សម្លេងឆ្នោត។

## តើខ្ញុំត្រូវបង្ហាញ អត្តសញ្ញាណប័ណ្ណពេលទៅបោះឆ្នោតដែរឬទេ ?

ពេលតែម្តងគត់ ដែលលោកអ្នកចាំបាច់ត្រូវបង្ហាញ អត្តសញ្ញាណប័ណ្ណ ពេលទៅបោះឆ្នោតនោះ គឺករណីលោកអ្នកទើបទៅបោះឆ្នោត ជាលើកទីមួយ ហើយមិនបានផ្តល់ លេខប័ណ្ណបើកបរ CA, លេខអត្តសញ្ញាណរដ្ឋ ឬ លេខ 4 ខ្ទង់ចុងក្រោយ នៃលេខសន្តិសុខសង្គមរបស់លោកអ្នក នៅពេលបំពេញការចុះឈ្មោះបោះឆ្នោត ។

## តើខ្ញុំអាចស្នើសុំសន្លឹកឆ្នោត ប្រើភាសាផ្សេងទៀត បានដែរឬទេ ?

បាន ដើម្បីស្នើសុំ សន្លឹកឆ្នោតរបស់លោកអ្នក ឬ ឯកសារបោះឆ្នោតណាមួយ ជាភាសាផ្សេងទៀតនោះ សូមទូរសព្ទទៅ លេខ :
**800-815-2666, ជម្រើស 3**

- ភាសា ដែលមានប្រើ : ភាសាអាមេនី ភាសាចិន ភាសាហ្វាស៊ី ភាសាហិនឌី ភាសាខ្មែរ/កម្ពុជា ភាសាកូរ៉េ ភាសារុស្ស៊ី ភាសាអេស្ប៉ាញ ភាសាតាហ្កាឡុក/ហ្វីលីពីន ភាសាថៃ ភាសាវៀតណាម

## តើដូចម្តេចដែលហៅថា សន្លឹកឆ្នោតគំរូ លក្ខណៈអន្តរសកម្ម ?

សន្លឹកឆ្នោតគំរូ លក្ខណៈអន្តរសកម្ម គឺជាជម្រើសមួយ សម្រាប់ម្ចាស់ឆ្នោត ដែលចង់មានលទ្ធភាពទទួលបាន និង គូសបោះឆ្នោត តាមការជ្រើសរើសរបស់ពួកគេជាលក្ខណៈឌីជីថល មុនពេលទៅដល់មណ្ឌលបោះឆ្នោត (ជំនួសឱ្យ កូនសៀវភៅស្តីពីសន្លឹកឆ្នោតគំរូ ធ្វើពីក្រដាស) ដោយប្រើកុំព្យូទ័រ ទូរសព្ទចល័ត ឬ ឧបករណ៍ផ្ទាល់ខ្លួន (**https://isb.lavote.net/**) ។

### កាលបរិច្ឆេទ សំខាន់ៗ
### ថ្ងៃទី 3 ខែវិច្ឆិកា | ការបោះឆ្នោត ជាសាកល

| | |
|---|---|
| ថ្ងៃចុងក្រោយ សម្រាប់ចុះឈ្មោះបោះឆ្នោត | **ថ្ងៃទី 19 ខែតុលា** |
| កូនសៀវភៅ ស្តីពីគំរូសន្លឹកឆ្នោត ផ្លូវការ ផ្ញើរតាមប្រៃសណីយ៍ | **ថ្ងៃទី 24 ខែកញ្ញា** |
| បញ្ញើសន្លឹកឆ្នោត តាមប្រៃសណីយ៍ ផ្ញើរចេញ | **ថ្ងៃទី 5 ខែតុលា** |
| ថ្ងៃចុងក្រោយ សម្រាប់បញ្ជូនសន្លឹកឆ្នោតបោះរួច ត្រឡប់មកវិញតាមប្រៃសណីយ៍ | **ថ្ងៃទី 3 ខែវិច្ឆិកា** |